# ដំណាំសណ្តែកបាយ

## I.សារៈប្រយោជន៍ដំណាំសណ្តែកបាយ

ជាទូទៅដំណាំសណ្តែកបាយមានសារៈសំខាន់ចំពោះមនុស្ស និងសត្វ ដូចជាៈ

-ម្សៅសណ្តែកៈ ធ្វើជាមីសួ , តៅហ៊ូ ។ល។

-គ្រាប់សណ្តែកៈ ធ្វើនំ , បង្អែម , សណ្តែកបណ្តុះ ។ល។

-ផ្លែខ្ចីៈ ធ្វើជាបន្លែស្រុះ , អន្លក់ , ម្ហូបផ្សេងៗ

-ដើម និងស្លឹកៈ ធ្វើជាជីស្រស់ កែប្រែគុណភាពដី និងជាចំណីសត្វ

## II.ការជ្រើសរើសពូជ

-ពូជសុទ្ធល្អ ធំ មិនបែក ឬស្វិត ទុំល្អ

-ពូជថ្មី ធន់នឹងជំងឺ និងសត្វល្អិតចង្រៃ

-ពូជមានដំណុះគ្រាប់ ៨៥ % ឡើង

-ពូជផ្តល់ទិន្នផលខ្ពស់

## III.ការជ្រើសរើសដី

ដំណាំនេះគេនិយមដាំនៅតាមតំបន់ខ្ពង់រាប , ភ្នំ , តាមជួរមាត់ទន្លេ ។ ប៉ុន្តែដីដែលសមស្របល្អសំរាប់ដំណាំនេះគឺៈ

-ដីមានស្រទាប់ជ្រៅ

-ដីធូរមិនជាំទឹក

-ប្រភេទដីល្បាយខ្សាច់

-ដីដែលមានលទ្ធភាពរស់នៅនៃពួកបាក់តេរី

## IV.រដូវកាលដាំដុះ (សណ្តែកបាយប្រភេទស្រាល )

-ដើមរដូវវស្សាៈ ដាំពីខែ មេសា-ឧសភា ដល់ខែ មិថុនា-កក្កដា ( ដីខ្ពង់រាប-ក្រហម )

-ពាក់កណ្តាលរដូវវស្សាៈ ដាំពីខែ កក្កដា-សីហា ដល់ខែ កញ្ញា-តុលា ( ដីទួលមិនលិចទឹក )

-រដូវប្រាំង (សំរក) ដាំពីខែ វិច្ឆិកា-ធ្នូ ដល់ខែ មករា-កុម្ភៈ

## V.បច្ចេកទេសដាំដុះ

### ១-ការរៀបចំដី

-ត្រូវភ្ជួរចោល ១ សារ ឬ ២ សារ អាស្រ័យនឹងស្មៅតិច ឬ ច្រើនក្នុងស្រែចំការ ដើម្បីកំចាត់ស្មៅ និងអោយមានបន្ទុកខ្យល់ចេញចូលបានល្អ ។

-ភ្ជួរជំរៅពី ១៥-២០ ស.ម រាស់បំបែកដី និងជ្រួយដីអោយផុសទុកដាំ ។

-នៅដើមឆ្នាំៈ ភ្ជួរដីចំនួន ២ ដងៈ

+លើកទី១ ភ្ជួរដីចោលអោយបាន១ខែ មុនពេលដាំ

+លើកទី២ ត្រូវភ្ជួរដីនៅពេលមានសំណើមល្អអាចដាំបាន

-នៅរដូវវស្សាៈ ការភ្ជួរដីដូចគ្នានៅដើមឆ្នាំដែរ

-នៅរដូវប្រាំងៈ គេអាចភ្ជួររាស់តែមួយសារដាំតែម្តងក៏បាន ។ តែបើភ្ជួរដី២ដង ត្រូវភ្ជួរដីលើកទី ២ ក្រោយភ្ជួរលើកទី១ ចំនួន ៧ ថ្ងៃប៉ុណ្ណោះ ខ្លាចសំណើមហួតអស់ពីក្នុងដី ។

## IV.ការប្រើប្រាស់ជីទ្រាប់បាត

### ១-ប្រភេទជីដែលត្រូវប្រើ

-ជីគីមីៈ ជី ១៥.១៥.១៥ និងជីផូស្វាតទូកមាស

### ២-កំរិតប្រើ

-ជី ១៥.១៥.១៥ ចំនួន ៨០ គ.ក្រ/១ហិកតា

-ជីផូស្វាត ចំនួន ៦០ គ.ក្រ/១ហិកតា

### ៣-ដំណាក់កាលប្រើ

-បាចល្បាយជីទាំងពីរ រួចរាស់លប់ក្នុងដីមុនពេលដាំ

## V.ការដាំដុះ

ការដាំសណ្តែកបាយមានវិធី ៣ យ៉ាងៈ

### ១-វិធីដាំដោយព្រួស ឬបាច

-ប្រើពូជពី ៣០ ទៅ ៤០ គ.ក្រ/១ហិកតា

-បាចគ្រាប់ពូជ រួចរាស់លប់១សារ ឬ ២ សារ

**២-វិធីដាំជាជួរ ឬឆូតជាគន្លង**

-ប្រើគ្រាប់ពូជ ២៥ គ.ក្រ-៣០ គ.ក្រ ក្នុង១ហិកតា

-ចន្លោះជួរដាំ ៥០ ស.ម

-ចន្លោះគុម្ព ១០-២០ ស.ម

-ចំនួនគ្រាប់ដាំ ៤-៥ គ្រាប់/គុម្ព

-ជំរៅគ្រាប់ដាំ ២-៣ ស.ម

-ចំនួនដើមទុក ២-៣ ដើម/គុម្ព

**៣-ការដាំដោយកាប់រណ្តៅ**

-ប្រើគ្រាប់ពូជៈ ៣០ គ.ក្រ ក្នុង ១ ហិកតា

-ចន្លោះជួរដាំ ៥០ ស.ម

-ចន្លោះគុម្ព ២៥ ស.ម

-ជំរៅគ្រាប់ដាំ ២-៣ ស.ម

-ចំនួនគ្រាប់ដាំ ៤-៥ គ្រាប់/គុម្ព

-ចំនួនដើមទុក ២-៣ ដើម/គុម្ព

**កំណត់ចំណាំ**

-បើដីមានជាតិជូរ ភ្ជួរបាចកំបោរស ពី ៣០០-៦០០ គ.ក្រ/១ហិកតា

-ក្រោយសណ្តែកអាយុ ១៥ ថ្ងៃ ត្រូវដកវំលែកកូនចេញ ទុកតែដើមណាដែលថ្លោសៗ

-វិធីដាំដោយព្រួស ឬបាចពិបាកក្នុងការធ្វើស្មៅ នាំអោយទទួលទិន្នផលទាបជាងវិធីសាស្ត្រផ្សេងៗ


**<u>សំរង់អត្ថបទ</u>**

-សៀវភៅដំណាំបន្លែ និងដំណាំរួមផ្សំ រៀបចំដោយអង្គការស៊ីដសេ-កម្ពុជា សហការជាមួយនាយកដ្ឋានក្សេត្រសាស្ត្រ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ១៩៩៧ ( ទំព័រ ៦២-៦៦ )

# ការថែទាំ និងប្រមូលផលសណ្តែកបាយ

## I.ការថែទាំ

### ១-ការជ្រួយដីកំចាត់ស្មៅ

ការជ្រួយដីកំចាត់ស្មៅ ប្រព្រឹត្តទៅចំនួន ២ ដងៈ

-លើកទី ១ ពេលសណ្តែកមានអាយុ ១៥ ថ្ងៃ ក្រោយដុះ

-លើកទី ២ ពេលសណ្តែកមានអាយុពី ២៥-៣០ ថ្ងៃ

ចំពោះការដាំដោយព្រួស វិធីសាស្ត្របន្ថយស្មៅត្រូវអនុវត្តតាមរយៈ

-ការរៀបចំដីអោយបានស្អាត

-ការហាលដីអោយស្ងួតល្អ មុនដាំ

-បាចគ្រាប់អោយបានស្មើល្អ

-ដាំឆ្លាស់មុខដំណាំ

### ២-ជំងឺ និងសត្វល្អិតចង្រៃ

**ក-សត្វល្អិតចង្រៃ** ជាទូទៅដំណាំនេះត្រូវសត្វល្អិតចង្រៃបំផ្លាញនៅគ្រប់ដំណាក់កាលនៃការលូតលាស់មានៈ ដង្កូវហ្វូង , ដង្កូវស៊ីស្លឹក និងដើម , ដង្កូវចោះផ្លែ , ដង្កូវស៊ីផ្លែ ។

វិធីកំចាត់

-ប្រើថ្នាំអាសូឌ្រីន ចំនួន ១-២ លីត្រ ក្នុង១ ហិកតា

-ថ្នាំឌីយ៉ាសេណុង ចំនួន ២លីត្រកន្លះ ក្នុង១ ហិកតា

**ខ-ជំងឺឫស**

ជំងឺនេះវាបង្កឡើងដោយវីរុសបណ្តាលអោយខូចខាតស្ទើរតែទាំងស្រុង

វិធីកំចាត់

-ដកដើមកើតជំងឺចោលអោយឆ្ងាយពីចំការ កប់ ឬដុតចោលតែម្តង

## II.ការប្រមូលផល

-គេអាចប្រមូលផលសណ្តែកបាយបាននៅពេលស្លឹកផ្នែកខាងក្រោមពណ៌លឿង , ផ្លែពណ៌ខ្មៅរលោង និងគ្រាប់ក្នុងផ្លែរលុង ។ ការប្រមូលផល វាអាស្រ័យតាមប្រភេទពូជ:

+ពូជខ្លះប្រមូលផលបានមួយលើក ក្នុងករណីពូជនោះទុំស្រុះគ្នាល្អ

+ពូជខ្លះប្រមូលផលពី ២-៣ លើក:

9លើកទី ១ ពេលសណ្តែកមានអាយុ ២ ខែ ក្រោយដាំ

9លើកទី ២ បេះក្រោយលើកទី ១ ចំនួន ២ សប្តាហ៍


**ឯកសារយោង**

-សៀវភៅដំណាំបន្លែ និងដំណាំរួមផ្សំ រៀបចំដោយអង្គការស៊ីដសេ-កម្ពុជា សហការជាមួយនាយកដ្ឋានកសិកម្មត្រសាស្ត្រ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ១៩៩៧ ( ទំព័រ ៦៦-៦៨ ) ។